សារព័ត៌មាន ខ្មែរផុស ស.រ.អ

Free

# KhmerPost USA

FREE BIWEEKLY CAMBODIAN ENGLISH NEWSPAPER SINCE 2007

978-677-7163 • VISIT KHMERPOST.US







## ព័ត៌មានសំខាន់ៗខាងក្នុង...

### លទ្ធផលបោះឆ្នោតនៅរ៉ូដអាយឡិន

*សូមអាននៅទំព័រទី ០៤*




### ក្រុមភ្លេងបុរាណមកពីជនបទខ្មែរសម្តែង...

*សូមអាននៅទំព័រទី ១០*




### ក្រុងឡូវែលធ្វើព្យុហយាត្រាប្រារព្ធខួប ៣០ឆ្នាំ....

*សូមអាននៅទំព័រទី ០៦*



### សមាជិកក្រុមប្រឹក្សាក្រុងឡូវែលស្នើពីភាក្សាច្បាប់

*សូមអាននៅទំព័រទី ០៨*



"នយោបាយសហរដ្ឋអាមេរិក"

# គណបក្សប្រជាធិបតេយ្យៈ"...ថ្ងៃស្អែកជាថ្ងៃថ្មីយើងនឹងស្តារប្រទេសយើងឡើងវិញ"

ដោយ ពិន សំខុន

បោះឆ្នោតថ្ងៃទី៦វិច្ឆិកា នេះ គឺជាកាសម្តែងមតិនៅក្នុង"តំបន់"ផង នឹងក្នុងសហព័ន្ធផង -មិនជាន់ខ្ពស់ ណានស៊ី ប៉ូឡូស៊ី បានចេញមកប្រកាសជ័យជំនះរបស់បក្សខ្លួនថា"...ថ្ងៃស្អែកជាថ្ងៃថ្មី យើងនឹងព្យាបាលប្រទេសយើងឡើងវិញ..." ប៉ុន្តែគណបក្សសាធារណរដ្ឋរបស់លោកប្រធានាធិបតី"ឌុណលត្រម" នៅរក្សាអាសនៈភាគច្រើននៅព្រឹទ្ធសភានៅឡើយ។ តទៅទំព័រទី០២



Elisabeth Warren (D)



Lori Trahan ( D )



Governor Baker & Polito



Maura Healy (D)



Edward Kennedy (D)



Richard Howe

តែប៉ុណ្ណោះ គឺឋិតនៅចំពាក់កណ្តាលអាណត្តិរបស់ប្រធានាធិបតី"ត្រម"មកពីគណបក្សសាធារណរដ្ឋ ដែលគណបក្សនោះមាន"សម្លេងភាគច្រើន"នៅសភាដំណាងរាស្ត្រផងនឹងនៅព្រឹទ្ធសភាផង។ នៅរាត្រីទី៦នោះ គណបក្សប្រជាធិបតេយ្យបានដណ្តើមយកឈ្នះឆ្នោតនៅសភាដំណាងរាស្ត្រ ហើយតំណាង











តមកពីទំព័រទី ០១

# គណបក្សប្រជាធិបតេយ្យ"ថ្ងៃស្អែកថ្ងៃថ្មី

ថ្ងៃនេះ ប្រជាពលរដ្ឋចេញទៅបោះឆ្នោតច្រើនជាងសព្វមួយដងជាទូទៅគេសង្កេតឃើញថា"អ្នកបោះឆ្នោត នៅពាក់កណ្តាលអាណត្តិប្រធានាធិបតី"ច្រើនយោងសេចក្តីសម្រេចចិត្តរបស់ខ្លួន ទៅតាម



Deborah Golberg (D)

ឥរិយាបទនយោបាយរបស់ប្រធានាធិបតី (ឥតឈរឈ្មោះ) ហើយយោងតិចតួចតែប៉ុណ្ណោះ ទៅតាមការឃោសនារបស់បេក្ខជន។

លោកប្រធានាធិបតី"ឌុណល ត្រម"បានបន្ថែមល្បឿនឃោសនានយោបាយ នាឱកាស១សប្តាហ៍



Eileen R.Duff

មុនការបោះឆ្នោតពាក់កណ្តាលអាណត្តិនោះ ដើម្បីជម្រុញឱ្យពាក្យសន្យាកាលពី២ឆ្នាំមុនរបស់លោកអាចទៅដល់គោលដៅបាន ដែលស្រដៀងគ្នានឹងនយោបាយរបស់ក្រុម"ស្តាំផុត"។ លោកបានប្រកាសថានឹង"ដកសញ្ជាតិអាមេរិកាំង" ពីអ្នកដែលមានសញ្ជាតិពីកំណើត ដោយរដ្ឋធម្មនុញ្ញមិនអាចការពារអ្នកទាំងនោះបានឡើយ -តើលោកចង់ដកសញ្ជាតិចេញពីពលរដ្ឋជំពូកណាមួយ? ក្នុងពេលជាមួយគ្នានោះ លោកក៏បានបញ្ជូនកងយោធាប្រមាន ១៥០ 00នាក់ ទៅព្រំប្រទល់"ម៉ិកស៊ីកូ" ដូចជាទៅធ្វើសង្គ្រាម តែគឺទៅទប់ទល់នឹងការប៉ុនប៉ងធ្វើអន្តោប្រវេសន៍ នៃប្រជាជនដែលឆ្លងប្រទេស "ម៉ិក-ស៊ីក" ហើយបំរុងសម្រុករកឆ្លងដែនចូលសហរដ្ឋអាមេរិកសោះ...។

អ្នកវិភាគនយោបាយបានវាយតម្លៃថា ការបន្ថែមល្បឿនឃោសនានេះ បានមកដល់"ចំណុចបែកបាក់ក្នុងបក្ស"មួយដែលក្រុមអ្នកគាំទ្រនយោបាយ"សាធារណរដ្ឋនិយម"នៅ"ស្តាំកណ្តាល"នោះគ្រាន់តែចង់បាន"នយោបាយដែលជម្រុញឱ្យមានការជឿនលឿននៃសេដ្ឋកិច្ច"តែប៉ុណ្ណោះ -តែលោក



Suzzane M. Bump (D)

"ត្រម"បានជម្រុញរហូតដល់មាន"ការប្រកាន់ពណ៌សម្បុរមនុស្ស" "ស្អប់ជនភៀសខ្លួន" ដែលបណ្តាលឱ្យជន"ស្តាំផុយនិយម"ខ្លះ ហ៊ានដល់ទៅអនុវត្តនី"អំពើហឹង្សា"ដូចជាបំផ្ទុះគ្រាប់បែកនៅវិហារពួកជីវនៅ"ពិតស្ប៊ឺគ"ជាដើម - នោះជាសកម្មភាពរបស់



William Galvin

ក្រុម"ស្តាំផុតនិយម"ដែលរួមប្រជុំដោយពួក KKK ផង ជាដើម។

តែរឿងនយោបាយសំខាន់បំផុត ដែលគណបក្សប្រជាធិបតេយ្យកុំគួននោះ គឺការធ្វើឱ្យនយោបាយព្យាបាលសុខភាពពលរដ្ឋក្លាយជាឡើងថ្លៃខ្ពស់, ពន្ធដារក៏ឡើងថៃ, ពលរដ្ឋក្រីក្រកាន់តែលំបាកវេទនា... ដែលជាប្រយោគ ណានស៊ី ប៉ូឡូស៊ី ប្រកាសនៅនាទីដំបូងបង្អស់ ដែលបក្សលោកស្រីទើបនឹងឈ្នះយកសភាមកវិញបាន - គេអាចយល់បានថាសភាដំណាងរាស្ត្រនឹងមានលទ្ធភាពស្របច្បាប់នឹងធ្វើទុក្ខលោកប្រធានាធិបតី ដែលមានអកប្បកិរិយា"ព្រហ៊ើន" នា២ឆ្នាំចុងក្រោយនេះ។

លោកប្រធានាធិបតី"ត្រម"បានថ្លែងថា"លោកមានសេចក្តីរីករាយណាស់ដែលបានធ្វើឱ្យព្រឹទ្ធសភាខាងលោកឈ្នះឆ្នោតបានហើយលោកក៏បានទូរស័ព្ទជូនពរក្រុមអ្នកឈ្នះឆ្នោតខាងសភាដំណាងរាស្ត្រហើយដែរ..."។





REACH THOUSANDS OF PEOPLE IN THE CAMBODIAN COMMUNITY WITH
COST EFFECTIVE NEWSPAPER ADVERTISING

PUBLISHING
Two Issues Every Month

READERSHIP
50,000 Monthly
600,000 Annually

DISTRIBUTION
70+ Locations in Lowell, MA
7,000 copies per month
25 Locations in Lynn & Revere, MA
1,000 copies per month
25 Locations in Providence & Cranston, RI
2,000 copies per month




Khmer Post USA
Distribution Locations:

- Households
- Markets
- Retail Businesses
- Restaurants
- Office Buildings
- Government Offices
- Chamber of Commerce
- Buddhist Temples
- Laundromats
- And Much More

KhmerPost USA is a free Cambodian-English biweekly newspaper serving Lowell, Chelmsford, Tyngsboro, Lynn and Revere, MA as well as Cranston and Providence, RI.

It was founded in 2007 by Soben Pin and partner Roger Pin. In 2010, they relocated the newspaper to Lowell to meet the demand for readership.

With an annual readership of 600,000, it is the only premier voice for the Cambodian-American community across the New England region.

www.khmerpost.us

# 2018 Massachusetts Midterm Election Results

By Soben Pin
Email: sobenpin@khmerpost.us

**U.S. House of Representatives**

There are nine congressional district seats in Massachusetts. Three congressional districts are where the large Cambodian communities live. They are 3rd, 5th and 6th congressional districts which include in Middlesex and Essex Counties.

The nation's second largest Cambodian population lives in Lowell, Massachusetts. It belongs in the 3rd congressional district, Middlesex County and is represented Congresswoman Niki Tsongas since 2013. In 2017, Tsongas announced that would not seek another term in 2018 election. Lori Trahan was elected on November 6th. Trahan received 62% (171,363) of the votes. Rick Green, a GOP candidate, received 33.5% of the votes (92,753).

5th congressional district is also part of the Middlesex County, in eastern Massachusetts. It includes the city of Revere where another Cambodian community lives and works. The district is represented by Kathrine Clark since 2013 when she won the special election for the U.S. House of Representatives to succeed Ed Markey. Clark won for the third term. She received 75.8% of the votes (232,752) and her opponent John Hugo (GOP) received 24.2% (74,138) of the votes.



Kathrine Clark



Seth Moulton

6th congressional district is the Essex County. The city of Lynn is part of this district. A thriving Cambodian community also lives here. It is represented by Democrat Seth Moulton since January 2015. Moulton won another term with 65.2% (216,282) votes and his challenger Joseph Schneider has 31.4% (104,379) votes.

**U.S Senate**

Elizabeth Warren (Dem) won another term to the U.S. Senate. Warren received 60.3% (1,617,101) votes. Geoff Diehl (GOP) has 36.3% (973,875) votes.

**Massachusetts Governor**

Charlie Baker (GOP) won a second term as governor of Massachusetts. Baker received has 66.9% (1,769,500) votes and his challenger Jay Gonzalez (Dem) has 33.1% (874.626) votes.



# 2018 Rhode Island Midterm Election Results

By Soben Pin
Email: sobenpin@khmerpost.us

Rhode Island midterm election results in 2018 remained blue. Incumbent Governor Gina Raimondo re-elected for the second term. Raimondo received 52.6% (196,977) votes and defeated a prominent Asian American Republican candidate Allan W. Fung who came short at 37.2% (139,276) votes. Daniel J. McKee (DEM) also retained the Lt. Governor post at 61.8% (225,266) votes and his challenger Paul Pence (REP) received 29.1%, (106,008) votes.

There is no change in the Congress from Rhode Island. Senator Sheldon Whitehouse (DEM) won the majority at 61.4% (228,679) votes and defeated his Republican chal-lenger Robert G. Glanders, Jr who's received 38.4% (143,711) votes.

There are two U.S. House of Representative in Rhode Island. They are from district 1 and district 2. District 1 re-elected David N. Cicilline (DEM) 66.7% the of votes; Patrick J. Donovan (REP) has 33.1% of the votes. Congressman James. R. Langevin also re-elected by his district by a high margin at 63.4% of the votes and the Republican candi-date Salvator G. Gaiozzo received 36.3% of the votes.

The Secretary of State Nellie M. Gorbea (DEM) received 67.3% of the votes (245,916) verse Pat V. Cortellessa (REP) received 32.5% (118,725) votes.

Attorney General Peter F. Neronha (DEM) won a high margin at 79.8%



Governor Gina Raimondo

(272,932) of the votes and his opponent Alan Gordon (Com) received 19.1% (65,312) of the votes.

General Treasurer Seth Magaziner (DEM) re-elected again by 64.9% (236,272) votes and his challenger Michael G. Riley (REP) lost at 35% with 127,319 votes.

On Question 1, 2, and 3, the Rhode Island voters approved $250 millions for school buildings, $70 millions for higher education facilities, and $47.3 millions for the green economy and clean water.

# លទ្ធផលនៃការបោះឆ្នោតពាក់កណ្តាលអាណត្តិ ឆ្នាំ ២០១៨ នៅរដ្ឋរ៉ូដអាយលិន

ដោយ សុបិន ពិន

Email: sobenpin@khmerpost.us

លទ្ធផលនៃការបោះឆ្នោតពាក់កណ្តាលអាណត្តិនៅរដ្ឋរ៉ូដអាយលិន ក្នុងឆ្នាំ ២០១៨ គណៈបក្សប្រជាធិបតិយ្យនៅតែជាបក្សទទួលការគាំទ្រឈានមុខ។ អភិបាលរដ្ឋដែលកំពុងកាន់តំណែង លោកស្រី ជីណា រ៉េម៉ុនដូ ត្រូវបានជាប់ឆ្នោតជាថ្មីឡើងវិញសម្រាប់អាណត្តិទីពីរនេះ។ លោកស្រីទទួលបានសម្លេងគាំទ្រចំនួន៥២,៦% ក្នុងចំណោមសម្លេងឆ្នោតទាំងអស់ (196,977) និងបំបាក់បេក្ខភាពមកពីគណៈបក្សសាធារណៈរដ្ឋដើមកំណើតអាមេរិកកាំង អាស៊ីដែលលេខធ្លោគឺលោក អាលេន ដែបបែលយូ ហ្វុង ដែលមានចំនួនគាំទ្រ ៣៧,២% វាស្មើរនឹង ១៣៩,២៧៦ សម្លេង។ លោក ដាលនី ជេ ម៉ាកឃី ក៏បានរក្សាតំណែងអភិបាលរងក្រុងដោយទទួលបានសម្លេង៦១,៨% ដែលមានចំនួន ២២៥,២៦៦ សន្លឹកឆ្នោត ចំណែកឯដៃគូប្រជែងរបស់លោកទទួលបាន២៩,១% ស្មើរនឹង ១០៦,00៨ សម្លេង។

ចំពោះសម្លេងឆ្នោតសម្រាប់ព្រឹទ្ធសភាវិញ គឺមិនមានការផ្លាស់ប្តូរនោះទេដោយសមាជិកព្រឹទ្ធសភារដ្ឋរ៉ូដអាលិនខាងគណៈបក្សប្រជាធិបតិយ្យ លោក សេលឌុន វ៉ាយហ៊ោស បានទទួលបានសំឡេងគាំទ្រភាគច្រើន ៦១.៤% (២២៨.៦៧៩) នៃសន្លឹកឆ្នោតសរុប ដោយបានផ្តួលគូប្រជែងខាងគណបក្សសាធារណរដ្ឋលោក រ៉ូប៊ឺត ជី គ្លេនឌ័រ ជេអ ដែលទទួលបានសម្លេងឆ្នោត ៣៨.៤% ឬ ១៤៣,៧១១ សន្លឹកឆ្នោត ។

សមាជិកសភាពីររូបនៅរដ្ឋ រ៉ូត អាលិន លោក ដេវីត អិន ស៊ីស៊ីលីន (David N. Cicilline) ខាងគណៈក្សប្រជាធិបតិយ្យ ដែលជាប់ឆ្នោតពី ដីសស្រីក ១ត្រូវបានបោះឆ្នោតគាំទ្រឡើងវិញ ដោយទទួលបានសម្លេង ៦៦,៧% ។ ចំណែក លោក ផាទ្រីត ជេ ឌូនូវ៉ាន (Patrick J. Donovan) ខាងគណៈបក្សសាធារណរដ្ឋមកដីសស្រីក ២ មកពីទទួលបានសម្លេងគាំទ្រ ៣៣,១% ។ សមាជិកសភាលោក ជេម អ លែងវីន (James. R. Langevin) ក៏ត្រូវបានត្រូវបានជាប់ឆ្នោតជាថ្មីឡើងវិញដោយទទួលសម្លេងគាំទ្រខ្ពស់រហូតដល់ ៦៣.៤% សន្លឹកឆ្នោត ដោយបានផ្តួលដៃគូរបស់លោកបេក្ខជនរបស់គណបក្សសាធារណរដ្ឋលោក

តទៅទំព័រទី ១៥

State of Rhode Island
Department of Administration
HealthSource RI

The State of Rhode Island has an exciting opportunity available within the Department of Administration for a:

CHIEF PUBLIC AFFAIRS OFFICER

Illustrative Examples of Work Performed:

As the senior staff member responsible for all of Healthsource RI's marketing and communications initiatives, this position is responsible for ensuring effective, coordinated and consistent messaging across all divisions of the organization, including many aspects of HealthSource RI's customer facing operations. This role entails writing, reviewing and editing information in different formats and across multiple platforms, as well as preparing and disseminating materials to staff, inter-governmental and external partners, stakeholders, customers and the public.

This position is a senior staff level role within the administrative offices of HealthSource RI, a division of the Department of Administration. HealthSource RI is the state's health benefits exchange.

This position will be responsible for HealthSource RI's marketing and communications initiatives, which will include setting a budget and managing related contracts, expenses and timelines.

Please Visit www.apply.ri.gov for more information.

Required Qualifications for Appointment:

Education: Such as may have been gained through: possession of a Master's Degree in Public Administration, Journalism or a related field from a college of recognized standing; and

Experience: Such as may have been gained through: considerable employment in a highly responsible position involving responsibility for the research, analysis, policy development and dissemination of information.

Or, any combination of education and experience that shall be substantially equivalent to the above education and experience.

To apply for this position, visit www.apply.ri.gov

AN EQUAL OPPORTUNITY EMPLOYER

We make health care easy.

Neighborhood has affordable plans for:
• Children and families
• Individuals
• Small businesses

យើងធ្វើឲ្យការថែទាំសុខភាពងាយស្រួល

Neighborhood មាន
គម្រោងដែលមានតម្លៃសមរម្យសម្រាប់៖
• កុមារ និងក្រុមគ្រួសារ
• បុគ្គលម្នាក់ៗ
• អាជីវកម្មខ្នាតតូច

Neighborhood Health Plan
OF RHODE ISLAND

Contact us today to learn more!
សូមទាក់ទងមកយើងខ្ញុំនៅថ្ងៃនេះ
ដើម្បីស្វែងយល់បន្ថែម!
www.nhpri.org



# DIVERSITY
## ADULT DAYCARE CENTER

*"A place where your loved ones can call home"*

**What is Adult Day Care:**
We understand that being a fulltime caregiver is a difficult job. When an elderly loved one needs additional care or supervision during the morning or day, it can create stress for the caregivers of the family. Many families think they have no choice but to quit their jobs or to admit their loved ones into a nursing home or assisted living facility. Diversity Adult Daycare Center (DADC) provides a safe supervised community where elderly adults can socialize, enjoy activities and get assistance with personal care. This will allow the caregivers of the family to have peace of mind when they have an appointment, work obligations or simply to enjoy some personal time.

**Benefits of Adult Day Care for Elderly Adults:**
Attending Adult Day Care has many positive benefits for elderly adults. Your loved ones do not have to be at home feeling lonely with no mental stimulation, when the caretakers are occupied. Being in an Adult Day Care creates a feeling of being in a community, where they can have fun and stay healthy with many activities. Your loved ones will look forward to having their independence and meeting their friends. Having friendships that you see every day promotes feelings of self-worth and camaraderie.

**Services we offer at DADC:**
- Nutritious meals and snacks
- Group fitness classes
- Education classes
- Group field trips and outings
- Fun daily entertainment and activities
- Assistance with personal care
- Salon service
- Transportation
- Monthly birthday parties
- Medical staff
- Gardening

**Who is an ideal candidate for Adult Day Care:**
- 55 years and older
- Southeast Asians & Hispanic (we are handicap accessible)

**Forms of payment that we accept:**
- We accept private pay
- All major insurances accepted

433 Elmwood Ave. Providence, R.I 02907
P: 401-427-1337 | F: 401-369-7818
www.diversityadc.com | diversityadc@gmail.com

**Se Habla Español**

We speak English, Spanish, Khmer, Lao, Hmong, Portuguese, Russian and Tagalog.
Come and schedule a free tour of our facility. We will provide free assessment and application assistance.
All major insurances and private pay accepted. Medicaid pays for adult day care, there is no cost to you.

# ក្រុងឡូវែលធ្វើព្យុហយាត្រាបានប្រារព្ធខួប ៣០ឆ្នាំនៃកម្មវិធី "City of Lights"

## លោកចន ផៅវើរ, នាយកនៃក្រុមហ៊ុន White Farley Interests nwgCa Grand Marshal សម្រាប់កម្មវិធីឆ្នាំនេះ

ដោយខ្មែរផុស ស.រ.អា

កម្មវិធីព្យុហយាត្រាដែលមានឈ្មោះថា ពន្លឺក្នុងទីក្រុង "City of Lights" សម្រាប់ឆ្នាំនេះ នឹងរៀបចំឡើងនៅថ្ងៃសៅរ៍ ទី២៤ ខែវិច្ឆិកា ខាងមុខនេះដោយចាប់ផ្តើមនៅពេលវេលាថ្ងៃត្រង់ តាមផ្លូវ ចាកស៊ុន (Jackson Street) នៅម៉ោង ៤:៣០ នាទីរសៀលនេះ។ ការធ្វើក្បួនដង្ហែរនេះ ដឹកនាំដោយលោក ចន ផៅវើរ (Grand Marshal John Power) ដោយចាប់ផ្តើមជាមួយក្រុមតន្ត្រី, រថយន្តដែលមានការតុបតែងចំរុះ, យានជំនិះសម័យដើម, ក្រុមភ្លេងព្យុហយាត្រា និងក្រុមណូអែលជាដើម។ ការធ្វើក្បួនដង្ហែរនេះ នឹងធ្វើដំណើរឆ្ពោះទៅផ្លូវ សិនត្រល (Central Street) បន្ទាប់មកផ្លូវ ម៉ារីម៉ាក (Merrimack Street) ហើយបន្តដំណើរទៅកាន់សាលាក្រុង។ ក្បួនដង្ហែរនឹងបញ្ចប់នៅមុខសាលាក្រុង ហើយលោកអភិបាលក្រុងឡូវែល វីលាម សាម៉ារាស, លោកផៅវើរ និងក្រុមណូអែល នឹងធ្វើការនាំមុខគេក្នុងការបើកសម្ពោធជាផ្លូវការដោយការបើកភ្លើងបំភ្លឺសាលាក្រុង និងបំពូលភ្លើងរូបដើមឈើគ្រីសសម្មាស។

សម្រាប់កម្មវិធីពេលថ្ងៃត្រង់ នឹងមានការជិះស្គីទឹកកក និងការកំសាន្តតាមលក្ខណៈគ្រួសារនៅទីតាំង JFK Plaza និងការរូបថតជាមួយនឹងតាណូអែលនៅឯទីតាំងសាលាក្រុង។ ម្ហូបអាហារ និងការដាក់លក់ផលិតផលផ្សេងៗទៀត នឹងរៀបចំនៅជុំវិញនៅទីតាំង JFK Plaza ហើយក៏មានការប្រគុំតន្ត្រីក្នុងពេលជាមួយគ្នាផងដែរ សម្រាប់ទស្សនា និងជាការកំសាន្ត។ ក្នុងកម្មវិធីនេះ ក៏នឹងមានសកម្មភាពផ្សេងៗទៀតរួមមាន ៖

"ការបញ្ចាំងខ្សែភាពយន្តនៅទីតាំង National Park Visitor Center ផ្លូវ ម៉ាឃីត ស្រីត (Market Street)

"ការដាក់តាំងបង្ហាញនិងលក់ផលិតផលសប្បកម្មនៅទីតាំង ឡូវែល ម៉ាក (Lowell Marks) នៅផ្លូវម៉ារីម៉ាក ស្រីត (Merrimack Street)

"ការគូរគំនូរ, ការដាក់តាំងបង្ហាញរូប និងកម្មវិធី វីស ហ្វេសស្ទីវល នៅទីតាំង អេឌុសិន ហ៊ល នៅខាងក្រោយព្រះវិហារអេនណេ (Anne's Church)

"កម្មវិធី Holley Jolly Trolley rbs; The National Park

"ការប្រគួតផឹកសុខកូឡាក្តៅ និងការប្រលងតុបតែងបង្អួចនៅឯទីប្រជុំជន downtown (ដោយមានបោះឆ្នោតជ្រើសរើសតាមការចូលចិត្តរបស់លោកអ្នក!)

លោកស្រី អេលីន ដណាហ៊្យូ អ្នកគ្រប់គ្រង

តទៅទំព័រទី ១៥

# LOWELL CELEBRATES THE 30TH ANNUAL CITY OF LIGHTS PARADE

## *John Power, Principle of Farley White Interests Will Be The Grand Marshal*

By KhmerPost USA



John Power



This year's City of Lights Parade will take place on Saturday, November 24 beginning at noon on Jackson Street at 4:30 p.m. The parade, led by Grand Marshal John Power, kicks off with bands, floats, specialty vehicles, antique cars, marching groups and Santa and Mrs. Claus. The parade marches onto Central Street then Merrimack Street as it makes its way to City Hall. Following the parade, which ends in front of City Hall, Santa, Mayor William Samaras and Grand Marshal Power will lead a countdown to the official lighting of City Hall and the Wannalancit tree.

The afternoon activities will include "ice" skating, family entertainment on JFK Plaza and photos with Santa in City Hall. Food and market vendors will set up around the plaza and a holiday sing-a-long will warm keep spectators gathering for activities and the entertained. Other activities include:

- A holiday movie screening at the National Park Visitor Center on Market Street
- An ornament craft workshop at Lowell Makes on Merrimack Street
- The Brush Art Gallery and Studios annual Festival of Wreaths in Edson Hall behind St Anne's Church
- The National Park's Holley Jolly Trolley
- Hot chocolate and window decorating contests at participating downtown businesses (vote for your favorite!)

"Every year, City of Lights celebrates Lowell's community spirit, creating wonder for children of all ages," said City Manager Eileen Donoghue.

Continued to Page 15


"កិច្ចប្រជុំក្រុមប្រឹក្សា"

កិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សា"កុំមូនីធី ទីមវើក" បានត្រូវកំណត់នៅថ្ងៃពុធ ទី២៨ វិច្ឆិកា ២០១៨ វេលាល្ងាច ម៉ោង៧គត់

នៅ១៥៥ផ្លូវមេរីម៉ាក ជាន់ទី២ បន្ទប់"ម៉ាជូរី ម៉ាក់ឌ័រមូទ" - សាធារណជនសូមស្វាគមន៍

BOARD MEETING

Community Teamwork monthly board meeting is scheduled on Wednesday, November 28th, 2018 at 155 Merrimack Street. Marjorie McDermott Board Room. 2nd Floor. Lowell, MA 01852. Meetings are called to order promptly at 7:00 P.M. Public is welcome.

ការិយាល័យ មេធាវី ថំមាស ស្តាលីយ៉ាណូស

Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852

- Immigration •អន្តោប្រវេសន៍
- Auto Crash •គ្រោះថ្នាក់រថយន្ត
- Divorce •លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766
www.thomasinlowell.com


Boch Honda West
299 Littleton Rd, Westford, MA 01886
EXIT 32 - OFF 495
Happy Honda Days
SALES EVENT
ធ្វើដំណើរជុំវិញពិភពលោក ៨ ដង
ហើយលោកអ្នក
នៅតែមានការការពារ
HOME OF THE
20 YEAR
200,000 MILE
LIMITED POWERTRAIN
★ WARRANTY ★
BOCH Honda West
HONDA
រួមបញ្ចូលជាមួយនឹង
រាល់ការទិញរថយន្តហុងដា ថ្មី
ដោយមិនគិតថ្លៃបន្ថែមទៀតឡើយ !
ធានាមានរថយន្តថ្មីនៅក្នុងស្តុក លើកលែងតែម៉ូឌែលជាក់លាក់មួយចំនួនប៉ុណ្ណោះ
ហើយការធានាគឺមិនអាចធ្វើការផ្ទេរបានឡើយ។ មិនមានសម្រាប់រជួល។
ច្បាប់ចម្លងលិខិតធានាមានសម្រាប់អតិថិជនមើលនៅកន្លែងលក់។
HONDA
មានវិញ្ញាបនបត្រផ្តល់
សិទ្ធធ្វើជាម្ចាស់ជាមុន
ផ្តល់ជាពិសេសសម្រាប់ធ្វើជាម្ចាស់ជាមុន
2015 Honda CIVIC LX VIN: FE246889 $12,998 BochHondaWest.com
2014 Honda CRV LX VIN: EL103799 $14,697 BochHondaWest.com
2016 Toyota CAMRY LE VIN: GR534026 $13,477 BochHondaWest.com
2012 Infiniti G37X VIN: CM670196 $13,829 BochHondaWest.com
2016 Honda CIVIC EX VIN: GE213530 $15,968 BochHondaWest.com
2016 Honda CIVIC EX VIN: GE205954 $17,490 BochHondaWest.com
2017 Dodge CARAVAN VIN: HR773731 $17,289 BochHondaWest.com
2017 Nissan MAXIMA S 3.5L VIN: HC447866 $20,488 BochHondaWest.com
2017 Honda ACCORD SPORT SE VIN: HA065625 $17,995 BochHondaWest.com
2015 Honda CRV EXL VIN: FL045556 $20,999 BochHondaWest.com
2017 Nissan FRONTIER SV V6 VIN: HN759961 $22,983 BochHondaWest.com
2017 Toyota PRIUS PRIME VIN: H3040428 $26,994 BochHondaWest.com
2016 Honda CRV EX-L VIN: GL032733 $21,557 BochHondaWest.com
2016 Honda PILOT EXL VIN: GB012749 $27,997 BochHondaWest.com
2016 Acura MDX TECH PACKAGE VIN: GB045640 $31,310 BochHondaWest.com
2015 BMW 640i XDRIVE CONVERTIBLE VIN: FD873174 $39,994 BochHondaWest.com
សម្រាប់ព័ត៌មានបន្ថែម
សម្រាប់ព័ត៌មានបន្ថែម
សូមទំនាក់ទំនង នីកុល ឈុន: nchhun@bochhondawest.com
ត្រូវការបុគ្គលិកផ្នែកលក់!
ទំនាក់ទំនងមកកាន់ ខេវិន រេជ: kcregg@bochhondawest.com
BochHondaWest.com | (978) 252-2125
HONDA

# សមាជិកក្រុមប្រឹក្សាក្រុងឡូវែលស្នើពិភាក្សាច្បាប់បោះឆ្នោតថ្មីជនភាគតិច

ដោយ ពិន សំខុន

លោក ”រ៉តនីយ អេលីយ៉ុត សមាជិកក្រុមប្រឹក្សាក្រុងឡូវែល បានស្នើប្រធានបទសុំពិភាក្សាច្បាប់ “បោះឆ្នោតថ្មីមួយ ដែលនឹងឱ្យសិទ្ធសហគមន៏អាចមានដំណាងរបស់ខ្លួនបាន...” ទៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាក្រុងឡូវែល កាលពីថ្ងៃអង្គារមុន, ដោយសារគេសង្កេតឃើញថាៈ សព្វថ្ងៃនេះ ដំណាងមកពីតំបន់“បែលវីឌ្យេ” តែ១នៃទីក្រុងឡូវែល មានដំណាងរបស់ខ្លួន ដល់ទៅ៧រូប នឹងតំណាងតែ២រូបប៉ុណ្ណោះ គឺមកពីតំបន់ឯទៀតចំនួន៧នៃក្រុងដដែល ។ ដោយសារតែរឿងចុងក្រោយនេះហើយ បានជាសាលាក្រុងឡូវែល ក៏បានទទួលពាក្យបណ្ដឹងពីឯកជនមួយក្រុម កាលពីជាង១ឆ្នាំកន្លះមុន ថា “ច្បាប់បោះឆ្នោតរបស់សាលាក្រុងឡូវែល បានរំលោភរដ្ឋធមនុញ្ញសហព័ន្ធ” ។

លោក ”រ៉តនីយ អេលីយ៉ុត បានត្រូវលោកអភិបាលក្រុង សាម៉ា”រ៉ាស ហាមឃាត់មិនឱ្យធ្វើសេចក្តីថ្លែងការក្នុងអង្គប្រជុំក្រុងនោះ ដោយសំអាងថា“ប្រធានបទនេះមិនមានសុវត្ថិភាពនឹងជជែកជាសាធារណទេ ត្រូវជជែកក្នុងបន្ទប់សម្ងាត់វិញ (៨សម្លេងព្រម+១សម្លេងមិនព្រម) ការហាមឃាត់នេះបាន ធ្វើឱ្យមានការប៉ះទង្គិចសម្លេងគ្នាយ៉ាងខ្លាំង ដោយលោក អេលីយ៉ុត ទាមទារមិនព្រមឱ្យពន្យាពេលពិភាក្សានេះ ទៅកាន់តែឆ្ងាយទេ ដែលនឹង“ធ្វើឱ្យចំណាយលុយកាន់តែច្រើននៅពេលចាញ់ក្តី” ។

ការទាមទារនោះប្រាថ្នាឱ្យមានច្បាប់បោះឆ្នោតថ្មីមួយ ដែលនឹងផ្តល់ឱ្យមាន“សមាជិកក្រុមប្រឹក្សាក្រុង៦រូប ដែលដំណាងឱ្យដំបន់៦ នៃក្រុងឡូវែលនឹងដំណាង៣រូបទៀត ដែលនឹងក្លាយជាដំណាងឡូវែលទាំងមូល”... ប៉ុន្តែទោះបីជាចុះចាញ់ដោយគ្មានអ្នកគាំទ្រពេលនេះក្តី គេអាចយល់បានថា“សមាជិកអង្គប្រជុំភាគច្រើន មិនបានការពារម្ចាស់លុយ ដែលជាអ្នកបង់ពន្ធដារនោះទេ”ពីព្រោះគ្រាន់តែចំណាយលើសំណង់វិទ្យាល័យថ្មីម្ចាស់លុយអ្នកបង់ពន្ធនឹងត្រូវចេញប្រាក់ចំណាយប្រមាណជា៣០០លានដុល្លា បន្ថែមពីលើចំណាយសម្រាប់សំណង់ដែលរដ្ឋបានសន្យាថាផ្តល់ឱ្យទៅហើយ ចុះទម្រាំចំណាយកំប៉ិកកំប៉ុកសម្រាប់មេធាវីការពាក្តីតូចមួយ តើមានអ្វីគួរឱ្យខ្វល់ខ្វាយទៅនោះ?

លោកអភិបាលក្រុងធ្លាប់បានឱ្យដឹងថា លោកអាចនឹងស្នើឱ្យឡូវែលធ្វើប្រជាមតិមួយថាៈ “តើគួរឱ្យឡូវែលរក្សាច្បាប់ដដែលនេះដែរឬទេ?...” ដែលក្រុមរបស់លោកសង្ឃឹមថានឹងទទួលចម្លើយថា “ព្រមឱ្យទុក”... ជាញយៗ គេសង្កេតឃើញតែសមាជិកក្រុមប្រឹក្សាតែ២រូបប៉ុណ្ណោះគឺៈ ”រ៉តនីយ អេលីយ៉ុត ហើយនឹង វីដា មើស្សៀ ដែលច្រើនតែរើកកកាយធ្វើឱ្យធ្លាយរឿងសម្ងាត់មួយចំនួនរបស់សាលាក្រុងឡូវែល ដែល“ក្រុមភាគច្រើន”ធ្វើឱ្យប៉ះពាល់ដល់“សិទ្ធិ”របស់ពលរដ្ឋខ្លួន ។



រ័ត្ននី អ៊ិលីយ៉ុត

សមាជិកក្រុមប្រឹក្សាសាលាក្រុងឡូវែល


## មកទេសចរណ៍រដូវស្លឹកឈើជ្រុះនៅតំបន់ម៉ារីម៉ាក់វ៉ាលេ









ក្រាន់តែធ្វើដំណើរតែកន្លះម៉ោងប៉ុណ្ណោះពីទិសពាយព្យនៃទីក្រុងប៉ូស្តុននឹងមកដល់តំបន់ម៉ារីម៉ាក់វ៉ាលេ។ការផ្លាស់ប្តូររដូវកាលបន្ថែមនៅភាពរស់រវើកនៅតំបន់នេះ។

មានថាមពលអស្ចារ្យដែលមិនអាចប្រកែកបាននៅតំបន់ ម៉ារីម៉ាក់វ៉ាលេ ដែលថាមពលដូចគ្នានេះដែលបានផ្តល់កំណើតដល់ប្រទេសរបស់យើង។ ក្រុងនិមួយក្នុងចំណោម ក្រុង និងទីប្រជុំជនទាំង 12 របស់យើងមានសម្រស់ និងទីកន្លែងប្លែកពីគេដែលលោកអ្នកត្រូវការ,

ដំណើរកម្សាន្តបន្ទាប់របស់លោកអ្នករង់ចាំលោកអ្នកនៅទី











Greater Merrimack Valley
Convention & Visitors Bureau
adventuresawait
merrimackvalley.org

MASSACHUSETTS
massvacation.com

merrimackvalley.org

សូមចូលទៅកាន់ Twitter និង Instagram @MerrimackValley

# វេជ្ជបណ្ឌិត សុខារិទ្ធិ មុី
# DR. SOKHARITH MEY, MD



## ចាប់ផ្តើមទទួលអ្នកជំងឺថ្មី
## ទាំងពីរការិយាល័យឡូវែល & លីន

**Now Accepting New Patients at both Offices**
**Family Medicine & Behavioral Health**
**Please Call Us To Enroll:**

Flu shot and vaccinations available now at both offices
ពេលនេះមានចាក់ថ្នាំការពារជំងឺផ្តាសាយធំ និងវ៉ាក់សាំងនានាទាំងពីរទីតាំង

**Lowell - (978) 455-7992**
**Lynn - (781) 780-7755**

ផ្នែកជំងឺទូទៅ និងជំងឺផ្លូវចិត្ត

មណ្ឌលពិនិត្យសុខភាពឡូវែល
**Lowell Primary Care Center**
1075 Westford St. Unit 204
Lowell, MA 01851

មណ្ឌលពិនិត្យសុខភាពលីន
**Lynn Primary Care Center**
280 Union St. Unit 402
Lynn, MA 01901

បុគ្គលិកនិយាយភាសាខ្មែរ/ Staff speak Khmer
We accept MassHealth, Medicare and other health insurances

# ក្រុមភ្លេងបូរាណមកពីជនបទខ្មែរសម្តែងនៅ MCC

ដោយខ្មែរផុស ស.រ.អា.

ក្រុមតន្ត្រីបូរាណមកពីជនបទខ្មែរ នៃខែត្រសៀមរាប មានឈ្មោះថា"សិល្បៈខ្មែរអមតៈ"បានមកដល់សហរដ្ឋ ហើយបានបើកឆាកសម្តែងភ្លេងខ្មែរដ៏ពិរោះកំដរគ្រូនឹងនិស្សិតនៅមហាវិទ្យាល័យ MCC នាទីក្រុងឡូវែល កាលពីថ្ងៃទី២៩ តុលា ២០១៨ វេលាម៉ោង១១ព្រឹក នៅចំពោះមុខនិស្សិតបរទេសនឹងនិស្សិតខ្មែរប្រមាណ២០០នាក់ ដែលបានមកទស្សនាយ៉ាងអប អរ។

ក្រុមសិល្បៈដ៏កម្រ ដែលមិនបានឆ្លងកាត់សាកលវិទ្យាល័យវិចិត្រសិល្បៈ ដូចសិល្បករឯទៀតដែលធ្លាប់បានបង្ហាញខ្លួនដល់ឡូវែលនេះ ក្រុមសិល្បៈករទាំង៥រូប មានយុវនារី២រូបផង បានសម្តែងស្នាដៃទ្រ ស្គរ ស្រដៀវ ឃឹម មានទាំងចាប៉ី នឹងគ្ហីតាផង បាននាំទស្សនិកជនឱ្យត្រឡប់អារម្មណ៍ទៅរកអតីតកាលប្រកបដោយបនោសញ្ចេតនាជាធម្មជាតិ តាមរយៈសម្លេងនៃដូរ្យតន្ត្រីបូរាណខ្មែរ ដោយចម្រៀងនឹងកំណាព្យស្នេហាផ្តោះផ្តងនៃយុវជន អាន ឆនផន (ជាស្ថាបនិក) នឹងយុវនារីផន សីមា ជូនដំណើរដោយសម្លេងគ្ហីតា របស់សាវ៉ាង ទូច ក្រោមបទអត្ថាធិប្បាយរបស់ នាង ហេងសំណាង បានធ្វើឱ្យបរិយាកាសក្លាយជាអន្លង់អន្លោច នឹងទៅដល់ជនបទនៃកម្ពុជាយ៉ាងក្រៃលែង។






មនុស្សដែលមានទេពកោសល្យរឹតតែពិបាករក គឺព្រឹទ្ធាចារ្យ ម៉ម ម៉ាន់ ដែលជាគ្រូបង្ហាត់របស់សិល្បៈករក្មេងៗឯទៀត ក្នុងនោះមានកូនស្រីគាត់ម្នាក់ផងដែរ គឺនាង ម៉ៅ មែន ដែលហ៊ានប្រកាសដណ្តើមចំណោះខាងវាយស្គរ ពីចំណោះដែលគេមានទម្លាប់បង្រៀងតែដល់ក្រុមបុរសតែប៉ុណ្ណោះនោះ ក៏បានបញ្ចេញស្នាដៃវាយស្គរសង្គ្រាមនឹងកូតទ្រខ្សែ ៣ ប្រាកដជាយ៉ាងចំណានពន់ពេក។

មែនហើយ! ក្រុមសិល្បៈជនបទបានចូលមកដល់ទីក្រុង ហើយមកដល់បរទេសនាសហរដ្ឋអាមេរិកទៀត ពួកគេមិនមែនសុំរស់ជាអ្នកក្រុងនោះទេ តែចង់ប្រាប់សប្បុរសជនថាសិល្បៈជនបទនោះ"នៅមានជីវិតនៅឡើយ"តែជីវិតនោះផុយស្រួយណាស់ ថ្វីត្បិតតែស្រឡាញ់ ប្រឹងរស់ពីសម័យ"ខ្មែរក្រហម" រហូតមកដល់សម័យក្រោយតមក យ៉ាងណាក៏ដោយក្តី ក៏មិនមានមនុស្សមកជួយថែទាំច្រើនទេ ហេតុនេះហើយ បានជាខិតខំបង្កើតកម្មវិធី"រថយន្តតន្ត្រីទិព្វខ្មែរ" ធ្វើជាសកម្មភាពបង្ហាញសិល្បៈតាមទីជនបទនានា បង្ហាត់បង្ហាញជាសាលាសាធារណឱ្យបានច្រើនកន្លែង ដើម្បីផ្សព្វជំនាញដែលមិនព្រមស្លាប់នេះ ជួយគ្នាឱ្យនៅ"ជាអមតៈ"ជារៀងរហូតតទៅ។









## ផ្តើមសេចក្តី

អារម្ភកថា

យើងសូមជូនរឿងថ្មីមួយទៀត គឺរឿង"កុមារ យោធិន្ទ"ជាប្រវត្តិកុមារប្រមាណជា១ពាន់នាក់ដែលបានចូលទៅបំរើក្នុងកងទ័ពតាំងពីអាយុ១០ឆ្នាំ នៅសាលារៀនមួយដែលកងខេមរភូមិន្ទបានបង្កើតឡើងបន្តពីអាណានិគមបារាំងក្នុងបំណងជួយចិញ្ចឹមកូនរបស់កងទ័ពបង្ហាត់បង្រៀនមុខវិជ្ជាដែលឪពុករបស់គេស្រឡាញ់ចូលចិត្តនឹងបានបូជាជីវិត ដើម្បីមាតុភូមិរបស់គេថែមទៀត។

ជារឿងពិតរបស់យុវជនមួយក្រុមរស់នៅដាច់ពីការថ្នាក់ថ្នមរបស់ឪពុកម្តាយមិនដូចក្មេង ឯទៀត គេចិញ្ចឹមកុមារទាំងនោះ ក្រោមវិន័យតឹងរឹងនៃកងទ័ពបង្ហាត់ហ្វឹកហ្វឺននឹងរៀនសូត្រវិជ្ជាចម្បាំងតាំងតែពីនៅតូច តែសាធារណជនមិនសូវដែលដឹងថា"សាលានោះជាអ្វី?បង្ហាត់បង្រៀនរបៀបណា? នឹងស្គាល់ថា ជាអ្វីនោះទេ" ក្រៅតែពីអ្នកនៅក្នុងក្រុងជាមួយនឹងអ្នកមិនឆ្ងាយពីបន្ទាយនៃកូនទាហ៊ានទាំងនោះ តែប៉ុណ្ណោះដែលស្គាល់ ហើយឱ្យឈ្មោះថា"ពួកក្មេងហ្វូង" ដែលជាឈ្មោះបកប្រែពីពាក្យបារាំងមកថា"Les enfants de troupe"។

# សាលាកងកុមារយោធិន្ទការមកដល់នៃសិស្សថ្មី (ត)

**ពិន សំខុន**

**ភាគ១ - សាលាកងកុមារយោធិន្ទ ការមកដល់នៃសិស្សថ្មី (ត)**

មែន! លោកកុម៉ងដង់មិនបានដឹងពីគោលបំណងនៃដំណើរទៅភ្នំពេញនោះទេ គឺព្រះអង្គម្ចាស់ យុវនាថ ទប់ព្រះទ័យមិនបន្តរការស្រឡាញ់របស់ព្រះអង្គមិនបានក៏សម្រេចរកអ្នកចូលទៅស្តីដណ្តឹងនាងកញ្ញា ទា គឹម យិន ពីម្តាយឪពុករបស់គេ។ ហេតុនេះហើយបានជាមិនយូរប៉ុន្មាន បន្ទាប់ពីព្រះអង្គយាងទៅភ្នំពេញតែម្នាក់ឯងនោះមក ក៏ស្រាប់តែមានលោកចៅហ្វាយខេត្រ អ៊ុង ញ៉ូច ក៏មកជួបនឹងលោកកុម៉ង់ដង់ ទឹម ថូ និយាយពិរឿងចូលស្តីសណ្តឹងកូនស្រីចៅកែបណ្ណាល័យថ្វាយព្រះអង្គម្ចាស់ តាមឱវាតសម្តេច សីហនុ ដែលបានទាក់ទងមករកលោកខៅហ្វាយខេត្រកំពុងចាម ឱ្យធ្វើជា"ចៅមហា"ជុំនួសព្រះអង្គ។

រំលងប៉ុន្មានខែកន្លងមក ពិធីភ្ជាប់ពាក្យក៏បានចាប់ផ្តើមនៅកំពុងចាម បន្តដោយពិធីមង្គលការដ៏គគ្រឹកគគ្រេងនៅមុខបណ្ណាគារទល់មុខផ្សារកំពង់ចាម ហើយពិធីក៏បន្តនៅសាលាខេត្រ រួចមកនៅភ្នំពេញក្នុងព្រះបរមរាជវាំងធ្វើឱ្យសាលាកុមាយោធិន្ទមានមុខមាត់ខ្ពង់ខ្ពស់ក្រៃលែងទៀតផង។ ព្រះអង្គម្ចាស់ក៏បញ្ចប់តួនាទីជាកុមារយោធិន្ទ តែមិនទៅចូលសាលាយោធាជាន់ខ្ពស់ឬជាន់ទាបណាទៀតទេ គឺទៅធ្វើការឯព្រះបរមរាជវាំងជាមួយព្រះកូណាតែម្តង រីឯព្រះអាណុចព្រះ



ទ្រង់នរោត្តម អាទិច្ចវង្ស សិស្សកុមារយោធិន ៥0ឆ្នាំក្រោយមក ថតនាឱកាសរៀបមង្គលការរាជបុត្រីពៅ និងរូបថតជាមួយម្តាយ ចន្ទ សីហា

អង្គម្ចាស់តែព្រះអង្គម្ចាស់ខេមានុរក្សហៅ"ម្ចាស់ក្រហ៊ា"ក៏ចាកចេញទៅជាមួយគ្នាដែរ។

នៅសល់ព្រះអង្គម្ចាស់២ព្រះអង្គទៀត ព្រះនាមនរោត្តម សុរិយោវង្ស រាងធាត់ នឹង អាទិច្ចវង្ស រាងស្គមខ្ពស់ ដែលនៅជាកុមាយោធិន្ទបន្តរទៅទៀត ជាព្រះរាជបុត្រទ្រង់នរោត្តម កន្តុល ជានាយករដ្ឋមន្ត្រី អ្នកទាំង២រមទម្យណាស់ មិនសូវធ្វើអ្វីឱ្យខុសប្លែកពីគេទេ ពិបាកយ៉ាងណាសុខចិត្តទ្រាំ មិនរអ៊ូរទាំអីទាំងអស់, អត់លុយចាយខ្លាំង ពេលខ្លះយកខោអាវថ្មីៗ ឬនាឡិការ ទៅបញ្ចាំនៅហាង"ម៉ៅសួរ"ឋិតនៅក្រោយបន្ទាយបានលុយ១០-២០រៀល នាំគ្នាទៅហូបបបរសនៅផ្សារពេលយប់ ឬទៅលួចមើលកុន នៅរោង"លំហែរាត្រី"រីករាយខ្លាំងណាស់, ប៉ុន្តែអាអ្នករត់ការ ដែលបានយកខោទៅបញ្ចាំវា




រូបសញ្ញាអន្តរជាតិសិស្សកុមារយោធិន

ស៊ីក្បាលកាត់អស់១០រៀលទៅហើយ ដល់ពេលទៅលួសមកវិញ ទើបបែកការតែវាហួសទៅហើយ ត្រូវតែយកមកវិញ បើមិនដូច្នោះទេ គេអាចយករបស់យើងដាច់តែម្តង។

ទ្រង់ អាទិច្ចវង្ស ចូលចិត្តដើរលេងត្រូវរ៉ូវគ្នានឹងកុមារយោធិន្ទ ពិន សំខុន អត្តលេខ ៦២៧ណាស់ មានគ្រែដេកជិតគ្នាចេញក្រៅសាលាក៏ទៅជាមួយគ្នា ហាត់កីឡាក៏ទៅជាមួយគ្នាដែរ។ តែពេលមួយនោះ ៦២៧ នឹងបងប៉ុន២៩៤ បាននាំទ្រង់អាទិច្ចវង្សទៅលេងផ្ទះមាររបស់គេម្នាក់ឈ្មោះ ពូសារីក នៅភូមិមេម៉ាយ គាត់ជាបុគ្គលិកពេទ្យសត្វត្រួតពិនិត្យខាងកាប់ជ្រូកសម្រាប់លក់ដូរក្នុងក្រុង, ក្នុងតួរនាទិនោះ គាត់តែងតែនាំយកពោះវៀនពោះតាំងជ្រូកដែលសេសសល់ មិនលក់នោះ មកផ្ទះរាល់ថ្ងៃ, ដល់ឃើញក្មួយៗមកលេង តែងតែយកគ្រឿងក្នុងទាំងនោះមកជប់លៀងក្មួយៗយ៉ាងបរិបូរនឹងយ៉ាងរីករាយនាចុងសប្តាហ៏ ពីព្រោះខ្លួនគាត់នឹងគ្រួសារទាំងមូលជាមនុស្សរួសរាយណាស់។ ស្ទើរតែរាល់អាទិត្យយើងតែងតែនាំគ្នា មកលេងគ្រួសារដ៏ធំរបស់គាត់មិនដែលដាច់ ជាពិសេសកូនប្រុសច្បងរបស់គាត់ឈ្មោះ រិន កូនស្រីបន្ទាប់ ២នាក់ នាងបងឈ្មោះ ម៉ាលីស នាងបន្ទាប់ឈ្មោះ ចន្ទសីហា ទាំង៣នាក់រៀននៅវិទ្យាល័យ"សីហនុ"ទាំងអស់ មានអាយុប្រហាក់ប្រហែលគ្នារាក់ទាក់ទទួលភ្ញៀវ រាប់អានជាមួយគ្នាដូចជាបងប្អូនបង្កើតដូច្នោះដែរ... ជាញយៗ យើងតែងតែនាំម្ហូបអាហារឆ្ងាញ់ៗទាំងនោះ មកចែកចាយដល់មិត្រក្នុងបន្ទាយថែមទៀតផង... មិនយូរប៉ុន្មានចំណងមិត្រភាពអ្នកទាំងអស់បានក្លាយជាចំណងស្នេហា នៅពេលរៀបនឹងចេញពីសាលាបងប៉ុនក៏បានចូលដណ្តឹងនាងម៉ាលីស រីឯព្រះអង្គម្ចាស់អាទិច្ចវង្ស ក៏ឱ្យម្តាយមកចូលស្តីដណ្តឹង នាង ចន្ទសីហា រៀបការនៅកំពង់ចាមទាំងគូរបន្តបន្ទាប់គ្នា មុនពេលចាកចេញពីសាលាកុមារយោធិន្ទបន្តិច...។

**ការរៀបចំរចនាសម្ព័ន្ធក្នុងសាលា**

សាលាកុមារយោធិន្ទមានសិស្សជាប្រចាំចំនួន៣00នាក់ នៅសិក្សារក្នុងបន្ទាយ ដែលមានតែមួយគត់នៅទីរួមខេត្រកំពង់ចាមនៃប្រទេសកម្ពុជាមានរបងជាប់គ្នានឹងសាលាខេត្តតែម្តង។ ថ្នាក់រៀនមានពីក៏រីតទី៥ (Cours Moyen 1) រហូតដល់៧ (Cours Superieur) ជាថ្នាក់សាលាបឋមសិក្សានឹងបន្តពីថ្នាក់ទី៦ ដល់ថ្នាក់ទី៣ នៃវិទ្យាល័យកុមារយោធិន្ទឥតមានខ្ពស់ជាងនេះទៀតទេ ។ សិស្សមួយចំនួនទៀត បានប្រឡងចូលវិទ្យាល័យ"ព្រះសីហនុ"ក៏ទៅរៀននៅទីនោះពេលថ្ងៃពេលល្ងាចនឹងថ្ងៃសម្រាកត្រូវចូលមកកាន់បន្ទាយវិញ រស់នៅជាសិស្សកុមារយោធិន្ទដូចអ្នកដ៏ទៃដែរ រៀននៅខាងក្រៅ ទើបមានថ្នាក់ខ្ពស់ដល់ថ្នាក់បញ្ចប់នឹងទៅមហាវិទ្យាល័យផង។ សិស្សម្នាក់ៗត្រូវមានសម្លៀកបំពាក់ជាកងទ័ពសម្រាប់ប្រើគ្រប់ពេល ដូចជាខោអាវដើរលេងខោអាវធ្វើការធម្មតា ខោអាវសម្រាប់ហាត់កីឡា ខោអាវសម្រាប់ចូលព្រៃស្បែកជើងគ្រប់ឈុតមានស្បែកជើងស្បែកខ្មៅ ស្បែកជើង"បាតា"កីឡា ស្បែកជើង"ប្រដឹកាំង" ស្បែកជើងចូលព្រៃ មានស្រោមជើងមកជាមួយនឹងមានមួកផងដែរ -កងទ័ពមានបើកទាំងមុង ភួយ ពូក កន្សែង... សិស្សមានបើកសៀវភៅសរសេរ៣ខែម្តង មានទាំងខ្មៅដៃ"ប៊ិច" ជ័រលុប...តែសាប៊ូថ្នាំដុសធ្មេញ ថ្នាំកក់សក់ ឥតមានបើកឱ្យទេ គឺត្រូវទិញខ្លួនឯង ជាមួយនឹងប្រាក់ខែ១២៩រៀល ដែលជាប្រាក់ប្រចាំខែនៃកុមារយោធិន្ទទាំងអស់ មិនថាសិស្សធំឬតូចទេ -ក្រៅពីនោះ គេមានទាំងសន្សំប្រាក់១២៩រៀលទុកក្នុងគណនីយ្យផ្ទាល់ខ្លួន ទុកឱ្យទៀត។ សិស្សកុមារយោធិន្ទទាំងអស់រៀនចេះប្រើអាវុធគ្រប់គ្នារៀនទាំងយុទ្ធសាស្រ្តយោធា តាមបែបយោធាបារាំងតែឥតមានកាន់អាវុធទេ។

មានកងកម្លាំងប្រដាប់អាវុធ សម្រាប់គ្រប់គ្រងវិន័យរបស់សិស្សកុមារយោធិន្ទចំនួន១"សិចស្យុង"ប្រមាណ៣0នាក់ទៀត ដែលនៅប្រចាំការមានទីលំនៅរស់ក្នុងបន្ទាយជាមួយសិស្ស តែនៅអាគារផ្សេងពីគ្នា ដែលចែកជាកងៈ -ពីកូនទាហ៊ានសក្តិ"ពលទោ" ដល់សក្តិ

តទៅលេខក្រោយ

# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

## AccuCare
### Home Care Agency
Group Adults Foster Care Program

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើងដែលមានបញ្ហារាំរ៉ៃផ្នែកសុខភាព ឬជរា ហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។





**បើឡើអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :**

- រស់នៅផ្ទះរដ្ឋ
- អាយុ ២២ ឆ្នាំឡើងទៅ
- មាសហែលស្តង់ដា

**ផលប្រយោជន៍ទទួលបាន :**

- ការថែទាំផ្ទាល់ខ្លួនមួយ ទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
- ផែនការថែទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់
- សមាជិកអាចទាក់ទងមក២៤ម៉ោង

***To be eligibled for GAFC you must:***

- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

***Benefits you will get:***

- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

**ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed**
**for Lowell, Lynn, Revere, and Boston**

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្តានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ

ដើម្បីចុះឈ្មោះសូមទាក់ទងមក
To register, please contact:
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

"ទស្សនៈមាននឹងក្រ"

# សហគមន៍ខ្មែរមានគន្លឹះថ្មីសម្រាប់អប់រំកូនរៀនឱ្យបានខ្ពស់

ដោយ ពិន សំខុន

សមាគមអាសេឡិក"ASALEC"ទើបនឹងអញ្ជើញសាស្ត្រាចារ្យបណ្ឌិត អាម៉ាយ៉ា មកពីសាកលវិទ្យាល័យ"Harvard" ឱ្យមកពន្យល់ពីវិធីអប់រំថ្មីមួយ កាលពីថ្ងៃទី៤វិច្ឆិកា នេះ នៅឡូវែល ដែលគ្រួសារនិមួយៗអាចនឹងមានលទ្ធភាពជួយបញ្ជូនសិស្សដែលបានរៀនចប់វិទ្យាល័យហើយនោះ ឱ្យអាចចូលទៅរៀននៅមហាវិទ្យាល័យបានយ៉ាងងាយស្រួល តើមានវិធីរបៀបណា? អនុវត្តន៍នៅគ្រួសារខ្មែរបានឬទេ? ត្រូវចំណាយលុយច្រើនប៉ុណ្ណា? គឺគេមានកម្មវិធីក្នុងប្រទេសនឹងកម្មវិធីអន្តរជាតិ...។

កូនខ្មែរយើងជាច្រើន តែងប្រទះការលំបាកនឹងឆ្លងកាត់រួច គឺរៀនចប់ថ្នាក់ទី១២ហើយ សិស្សដែលរៀនពូកែ ក៏ឡើងទៅរៀននៅមហាវិទ្យាល័យមិនបានដោយគ្មានការណែនាំត្រឹមត្រូវ ឬក៏ថា ចំណាយលុយច្រើន រកអាហារូបករណ៍មិនបាន... តើត្រូវធ្វើយ៉ាងណា? ស្ថិតិជំរឿនប្រជាជនឆ្នាំ២០១០ និយាយថា: កូនខ្មែរប្រមាណ0.0១ភាគរយប៉ុណ្ណោះដែរ បានបន្តរទៅមហាវិទ្យាល័យ តើហេតុអ្វី? ចំណែកសេចក្តីរាយការណ៍បច្ចុប្បន្ន ក៏និយាយថា អ្នកដែលជំពាក់លុយថ្លៃសាលាដែលខ្លួនបានរៀន មានចំនួន ១,៦ ទ្រីល្យុងដុល្លា។

វិធីនោះគឺជាកម្មវិធីផ្លូវការមួយឈ្មោះថា "College Planning"របស់អង្គការ"HIPE" ដែលបណ្ឌិត អាម៉ាយ៉ា ខ្លួនឯងនឹងគ្រួសារគាត់



អនុបណ្ឌិត អាម៉ាយ៉ា

ជាជនជាតិភាគតិចដែរនោះ បានអនុវត្តន៏រហូតដល់បានជោគជ័យទាំង២នាក់រហូតដល់ទៅ៧ឯកទេស ដោយទទួលបានសញ្ញាប័ត្របណ្ឌិតសាកលវិទ្យាល័យ"ហាវើដ" ហើយដោយមិនមានជំពាក់ប្រាក់ត្រូវសងធានាគាររដ្ឋច្រើនឆ្នាំ យ៉ាងលំបាកវេទនានោះទេ ។ បណ្ឌិត អាម៉ាយ៉ា និយាយថា "កីឡាករពូកែ ពីព្រោះគេមានគ្រូបង្ហាត់ - រីឯនិស្សិតពូកែក៏ត្រូវមានគ្រូបង្ហាត់នោះដូចគ្នាដែរ គឺកម្មវិធីនោះ នឹងមានអ្នកមកណែនាំកូនយើងតាំងពីថ្នាក់ទី៨ឬ៩ឡើងទៅរយៈពេលវែង រហូតដល់ចប់មហាវិទ្យាល័យ ទើបចប់ភារកិច្ច"។ តើគេនឹងណែនាំអ្វីខ្លះ? តើការណែនាំនោះនឹងទទួលបានអ្វី?

គឺដំបូងគ្រូបង្ហាត់ឬ"Coach"នឹងសិក្សាពីសិស្សឱ្យដឹងថា តើទិសដៅអនាគតសិស្សចង់បានអ្វី? ចង់រៀនមុខវិជ្ជាអ្វីទៅថ្ងៃមុខ ដើម្បីរៀនឱ្យឆាប់ចប់ចំគោលដៅ? សាលាណាមួយដែលមានជំនាញរបស់សិស្សនោះ? ក្នុងចំណោមសាលាដែលត្រូវជំនាញ តើសាលាណាមួយដែលផ្តល់តម្លៃនឹងជំនាញប្រសើរជាងគេ? ត្រូវសរសេរសុំអាហារូបករណ៏របៀបណា? សម្រាប់ទៅសាលាណាមួយ? នៅមហាវិទ្យាល័យហើយក្តី ក៏នៅតែបន្តរការណែនាំរហូតដល់ចប់ចុងចប់ដើម។

បើជួយច្រើនយ៉ាងនេះ តើគ្រួសារសិស្សនឹងត្រូវចំណាយប៉ុន្មាន? មែន! វានឹងមានការចេញថ្លៃខ្លះដែរ គឺតម្លៃតិចតួចបំផុតដើម្បីឱ្យសិស្សមានសមាជិកភាពក្នុងអង្គការ"HIP ដើម្បីឱ្យអាចណែនាំរយៈពេលយ៉ាងហោចណាស់ ក៏៥ឆ្នាំនៃអម្លុងពេលសិក្សាក្នុងមហាវិទ្យាល័យ ដែលត្រូវការអាហារូបករណ៏ចំណាយខ្ពស់កប់ពពកគ្រប់ជំពូកនោះដែរ -តែសិស្សមិនបានចេញលុយទាំងនោះខ្លួនឯងទេ។

ការមិនបានរៀនទៅឆ្ងាយធ្វើឱ្យគ្រួសារ "ក្រីក្រ" ពីព្រោះបានប្រាក់បៀវត្សតិច ការងារក៏មិនសូវសម្បូរ ពីព្រោះគ្មានអ្វីប្រជែងយកការងារល្អៗឈ្នះគេ ដល់ចាស់ខ្លួនទ្រុឌទ្រោមដោយធ្វើការធ្ងន់ ហើយបើបានប្រាក់ចូលនិវត្តន៏ក៏បានតិច ធានាជីវិតមនុស្សចាស់នឹងជម្ងឺច្រើនមិនបាន ដូច្នេះហើយបានជា មាតាបីតាមានភារៈកិច្ចបញ្ជូនកូនចៅទៅរៀនឱ្យបានឆ្ងាយកុំឱ្យខានពីពេលនេះតទៅកុំឱ្យគ្នាមានវាសនាអន់ជាងចាស់ជំនាន់មុនឱ្យសោះ។

ព័តិមានបន្ថែម"អាសេឡិក"(978)942 1641

MARCOTTE LAW FIRM
ក្រុមហ៊ុនមេធាវី Marcotte
45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229

- សេចក្តីអន្តរាយដល់បុគ្គល
- សំណងបុគ្គល
- ពិការភាពដោយសន្តិសុខសង្គម
- បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
- ច្បាប់គ្រួសារ និងផែនការអចលនទ្រព្យ
- បណ្តឹងវិវាទទូទៅ
- បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍
- ច្បាប់ធានារ៉ាប់រង
- ការរំលោភបទព្រហ្មទណ្ឌ
- គ្រោះថ្នាក់ចរាចរណ៍
- គ្រោះថ្នាក់នៅការដ្ឋាន
- បំណុលអចលទ្រព្យ

មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទមកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ
(978) 458-1229
www.marcottelawfirm.com



CONWAY
INSURANCE AGENCY
រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវេយបានបម្រើសហគមន៍ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងឡែន ។
យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :
ការធានារ៉ាប់រងគ្រួសារ
- រថយន្ត
- ផ្ទះ
- ផ្ទះល្វែង
- គ្រឿងអលង្ការ
- វត្ថុសិល្បះ
- វត្ថុបុរាណ

ការធានារ៉ាប់រងជំនួញ
- អចលនវត្ថុ
- សុវត្ថិភាពជំនួញ (Liability)
- សុវត្ថិភាពជំនាញ (Professional Liability)
- ពិការ (Worker's Compensation)
- បនដស៍ (Bonds)
- អ្នកមើលថែឡាន និងការលក់ឡាន
- ធានារ៉ាប់រងពិការភាព និងជីវិត
- កម្មវិធីពិសេសផ្សេងៗទៀត

77 E. Merrimack Street. Lowell, MA 01852
Tel: 978-454-5054|Fax 978-453-2480
www.conwayinsurance.com
សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង







*State of Rhode Island*
*Department of Administration*
***Department: MILITARY STAFF***

The State of Rhode Island has an exciting opportunity available within the Department of Administration for a:

## *HVAC SHOP SUPERVISOR*

**Required Qualifications for Appointment:**

**Education:** Such as may be gained through: graduation from a senior high school; and

**Experience:** Such as may have been gained through: employment in a responsible position in the field of heating ventilating and air conditioning; employment as a journeyman refrigeration mechanic; employment in the field of energy management with experience in energy management and preventive maintenance.

Or, any combination of education and experience that shall be substantially equivalent to the above education and experience.

**SPECIAL REQUIREMENTS:** At the time of appointment, must possess a R.I. State Refrigeration License issued by the State Department of Labor and Training, Office of Professional Regulation (Pipefitters/Refrigeration) and must maintain such license as a condition of employment.

Candidates are required to possess a valid drivers license and are required to maintain that license as a condition of employment. Within the State Military Department, all employees are subject to National Agency Criminal Investigation (NACI) and a State Bureau of Criminal investigation(BCI).

**Illustrative Examples of Work Performed:**

To supervise and work in conjunction with the activities of a skilled trades staff engaged in a program of buildings and grounds maintenance.

To supervise the maintenance and repair of various types of heating, ventilating and air conditioning systems.

To maintain, adjust and repair various energy management systems located throughout the facility.

To supervise and work in conjunction with the operation, maintenance, repair and gas reclamation for a wide variety of commercial and household refrigeration and ice making units, using a variety of refrigeration gases and medium.

To supervise various vendors and contractors engaged in building maintenance services and repairs.

To maintain records of materials used and prepare reports of progress on specific assignments.

To make inspections of buildings and grounds to determine repairs and maintenance needed.

To supervise and maintain the preventive maintenance program for the heating ventilating and air conditioning systems.

To read blueprints for specifications for various maintenance jobs, to estimate materials, and to requisition supplies.

To assist in obtaining clarification of billing payments, requisitions, purchase orders and invoices.

To submit written requests for supplies and equipment, including the determination of kind, size, quantity and quality.

To do related work as required. **Please Visit www.apply.ri.gov for more information.**

To apply for this position, visit www.apply.ri.gov

State of Rhode Island
Department of Administration
**Rhode Island Department of Transportation**

The State of Rhode Island has several exciting opportunities available. To apply for this position, visit www.apply.ri.gov

## ELECTRICAL INSPECTOR (TRANSPORTATION)

**$45,469.00 - $52,085.00 Annually**

**Education**: Such as may have been gained through: completion of senior high school; and

**Experience**: Such as may have been gained through: employment as a journeyman electrician which involved interpreting complex electrical construction wiring diagrams.

**Or**, any combination of education and experience that shall be substantially equivalent to the above education and experience.

**SPECIAL REQUIREMENTS:**

At the time of appointment, must possess a Class B journeyman electrician's license issued by the Rhode Island Board of Examiners of Electricians and must maintain such license as a condition of employment.

## HIGHWAY MAINTENANCE TRAFFIC ELECTRICIAN

**$51,020.00 - $57,488.00 Annually**

**Education:** Such as may have been gained through: graduation from a senior high school; and

**Experience:** Such as may have been gained through: employment as an electrician which involved interpreting complex electrical construction wiring diagrams.

Or, any combination of education and experience that shall be substantially equivalent to the above education and experience.

**SPECIAL REQUIREMENTS:**

1. At the time of appointment and continually thereafter:

1.1. Must possess and maintain a Class B Electrician license issued by the Rhode Island Board of Examiners of Electricians and must maintain such license as a condition of employment.

1.2. Must possess and maintain a Rhode Island Commercial Driver's License (CDL), Class B with airbrakes, and must maintain such as a condition of employment.

1.3. Compliance with the USDOT Federal Regulations of the Omnibus Transportation Employee Testing Act of 1991 and the State of Rhode Island's Drug & Alcohol Testing Program Policy & Procedures is a mandatory requirement and a condition of continued employment.

1.4. Must be physically qualified to perform assigned duties as evidenced by a physician's certificate.

1.5. Must possess and maintain a Hoisting License with an Aerial Lift Restricted Endorsement and Hydraulic Crane Restricted Endorsement, as regulated by the Rhode Island Department of Labor & Training.

Please Visit www.apply.ri.gov for more information.

តមកពីទំព័រទី ០៩

## ក្រុងឡូវែលធ្វើព្យុហយាត្រាបានប្រារព្ធ

## LOWELL CELEBRATES THE 30TH...

ទីក្រុងបានមានប្រសាសន៍ថា "ជារៀងរាល់ឆ្នាំ កម្មវិធីពន្លឺក្នុងទីក្រុងនៃពន្លឺរៀបចំឡើងជាស្មារតីសហគមន៍ឡូវែលដែលបង្កើតនូវភាពអស្ចារ្យសម្រាប់កុមារគ្រប់វ័យ"។ លោកស្រីបានបន្តថា "ខណៈពេលដែលមើលត្រលប់ទៅដើមកំណើតប្រពៃណីរបស់យើងនៅក្នុងទសវត្សទី៥0 សម្រាប់អង្គការរបស់យើង"។ លោលបន្តថា "រយៈពេល ១៩ ឆ្នាំ ដើមឈើណូអែលរបស់ Wannalancit Mill វាគឺជានិមិត្តសញ្ញាមួយនៃថ្ងៃឈប់សម្រាក និងហើយក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ យើងបានបន្ថែមទីតាំងសម្រាប់សត្វសត្វក្តាន់ នៅទីតាំង Cross River Center ស្ថិត

"While harkening back to its traditional origins in the '50s and 60s, it has evolved over the last thirty years into an event that highlights Lowell's holiday traditions—past and present—while promoting our creative organizations, retailers and restaurants."

John Power, principal of Farley White Interests and owner of the Wannalancit Mills, this year's City of Lights Grand Marshal says "Giving back to the community is imperative to our organization."



និង៦0 វិញ វាបានវិវត្តនៅក្នុងរយៈពេល៣0ឆ្នាំចុងក្រោយ នេះប្រែក្លាយជាព្រឹត្តិការណ៍មួយដែលបង្ហាញឱ្យ ឃើញពីរបៀបរបបនៃការធ្វើកម្មវិធីសម្រាប់ការឈប់សម្រាករបស់ទីក្រុងឡូសែល -តាំងពីអតីតកាលនិងបច្ចុប្បន្ន-ខណៈពេលវាកំពុងលើកកម្ពស់ការច្នៃប្រឌិតរបស់ភោជនីយដ្ឋាន, អ្នកលក់ដូរ និងអង្គការជាច្រើនរបស់យើង"។

លោក ចន ផៅវើរ អគ្គនាយកក្រុមហ៊ុន Farley White Interests និងម្ចាស់នៃរោងចក្រវ៉ានណាឡាសីត ម៉ាល (Wannalancit Mills) និងជា Grand Marshal សម្រាប់ឆ្នាំនេះ បានឱ្យដឹងថា "ការផ្តល់ឱ្យសហគមន៍វិញ វាគឺជាការចាំបាច់ នៅផ្លូវ ១00១ Pawtucket Blvd ក្រុងឡូវែល ។ ការកោតសរសើរពីសហគមន៍ និងការអបអរ បាននាំឱ្យមានមនុស្សជាច្រើនឱ្យលោកទទួលយកជាកិត្តិយសធ្វើជា Grand Marshalសម្រាប់ឆ្នាំនេះ"។

ចាប់តាំងពីឆ្នាំ ១៩៩៩ ទីតាំង Wannalancit Mills បានក្លាយកន្លែងសម្រាប់ការសម្រាកលំហែមួយដែលត្រូវបានរៀបចំជាមួយនឹងភ្លើងបៃតងរាប់ពាន់ដោយបង្កើតចេញជារូបភាពដើមឈើដ៏ធំមួយហើយមានផ្កាយនៅខាងលើបំផុត។

Power added "For 19 years the Wannalancit Mill smokestack Christmas tree has been an iconic symbol of the holiday spirit and in recent years we have added a reindeer field at Cross River Center, located at 1001 Pawtucket Blvd Lowell. The appreciation from the community and joy it brings to so many makes this acceptance of Grand Marshal truly an honor."

Since 1999 the Wannalancit Mills smokestack has become a holiday beacon with thousands of green lights creating a giant tree that is topped off by a star.

តមកពីទំព័រទី ០៤

## លទ្ធផលនៃការបោះឆ្នោត...

សាលវ៉ាធ័រ ជី ចាអូស្ស៊ូ (Salvator G. Gaiozzo) ទទួលបានសម្លេងឆ្នោតតែ ៣៦.៣% ប៉ុណ្ណោះ។

រដ្ឋលេខាធិការ លោកស្រី នេលី អេម គួបេ (Nellie M. Gorbea) ខាងគណៈបក្សប្រជាធិបតយ្យ បានទទួលសម្លេងគាំទ្រចំនួន៦៧,៣% នៃឆ្នោតសរុប២៤,៥,៩១៦សម្លេង ចំណែកលោក ផាត វី ខូតេលេសា (Pat V. Cortellessa) មកពីគណបក្ស សាធារណៈរដ្ឋ បានទទួលការគាំទ្រ ៣២,៥% (១១៨,៧២៥ សម្លេង) ។

អគ្គមេធាវីលោក ផីតធ័រ អែស នេរ៉ុនហា (Peter F. Neronha) ខាងគណៈបក្សប្រជាធិបតិយ្យទទួលបានការគាំទ្រខ្លាំងដោយមានភាគរយនៃសម្លេងឆ្នោតរហូតដល់ទៅ៧៩,៨% (២៧២,៩៣២) នៃសន្លឹកទាំងអស់ និងគូប្រជែងរបស់លោក ផីតធ័រ គឺលោក អេលេន ជូរដុន (Alan Gordon) ដែលទទួល បានសំលេងឆ្នោតចំនួន ១៩,១% (៦៥,៣១២) ។

អគ្គនាយកនៃរតនាគារជាតិ លោក សេថ ម៉ាកាស៊ីនន័រ (Seth Magaziner) ខាងគណៈបក្សប្រ ជាធិបតយ្យត្រូវបានជាប់ឆ្នោតម្តងទៀតដោយទទួលបានការគាំទ្រ៦៤,៩% (២៣៦,២៧២សម្លេង) ចំណែកគូរប្រជែងរបស់លោកគឺ មីឆែល ជី រីលី (Michael G. Riley) បានចាញ់ឆ្នោតដោយទទួល បានការគាំទ្រតែ៣៥% ដោយទទួលសន្លឹកឆ្នោត១២៧.៣១៩សម្លេង។

សម្រាប់សំណួរលេខទី ១,២ និងទី ៣ អ្នកបោះឆ្នោតនៅរដ្ឋ រ៉ូដ អាយលិន បានអនុម័តទឹកប្រាក់ចំនួន ២៥0លានដុល្លារសម្រាប់អាគារសាលារៀន,៧0លានដុល្លារសម្រាប់គ្រឹះស្ថានឧត្តមសិក្សា និង ៤៧.៣ លានដុល្លារសម្រាប់សេដ្ឋកិច្ចបៃតង និងទឹកស្អាត។


All Care Resources

កម្មវិធីថែទាំសុខភាពសម្រាប់មនុស្សពេញវ័យរបស់គម្រោង អល ខែរីសស (All Care Resources) ត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីជួយដល់អ្នកជំងឺ និងអ្នកថែទាំដែលរស់នៅជាមួយគ្នានៅក្នុងសហគមន៍តាមរយៈការផ្តល់នូវការគាំទ្រផ្នែកវេជ្ជសាស្ត្រ, ការអប់រំ និងប្រាក់កម្រៃ។

លក្ខខណ្ឌនៃការដាក់ពាក្យក្នុងកម្មវិធីនេះ :

-អ្នកដែលមានជំងឺត្រូវមានអាយុ១៦ឆ្នាំនិងច្រើនជាងនេះ ហើយត្រូវការការថែរក្សានិងការមើលការខុសត្រូវសម្រាប់សកម្មភាពនៃការរស់នៅប្រចាំថ្ងៃ និងត្រូវមានស្តង់ដាម៉ាស់ហែល។

-អ្នកថែទាំត្រូវមានអាយុយ៉ាងហោចណាស់១៨ឆ្នាំ រស់នៅក្នុងផ្ទះជាមួយនឹងអ្នកជំងឺតែអ្នកមើលថែនោះមិនត្រូវជាប្រពន្ធ រឺស្វាមី, អ្នកទទួលសិទ្ធជាអាណាព្យាបាលស្របច្បាប់របស់អ្នកជំងឺ ឬជាឪពុកម្តាយដែលមានកូនមិនទាន់ពេញវ័យនោះទេ។

-អ្នកថែទាំ និងអ្នកជំងឺត្រូវតែរស់នៅជាមួយគ្នា ហើយអ្នកថែទាំត្រូវតែមានលទ្ធភាពមើលថែអ្នកជំងឺពេញ២៤ម៉ោងក្នុង៧ថ្ងៃក្នុងមួយសប្តាហ៍។

ប្រសិនបើអ្នកមានចំណាប់អារម្មណ៍ សូមទំនាក់ទំនង លីនា ឌៀប (Lyna Dep) ដែលស្ទាត់ជំនាញភាសាខ្មែរ តាមរយៈលេខទូរស័ព្ទ ៧៨១-២៤៤-១១១៥ ។






CITY OF
LIGHTS
11-24-18
ម៉ោង 12 រសៀល - 4 ល្ងាច ការប្រគួតផឹកសុខកូឡាក្ដៅ
នៅ ដោនថោន ឡូវែល
ម៉ោង 12 រសៀល - 5 ល្ងាច កម្មវិធី វើស ហ្វេសស្ទីវល នៅព្រះវិហា
ម៉ាសុនិច
ម៉ោង 1 រសៀល - 3 រសៀល កម្មវិធីថតរូបជាមួយតាណូអែល -
នៅសាលាក្រុង
ម៉ោង 1 រសៀល - 5 ល្ងាច
កម្មវិធីដាក់តាំងលក់ផលិតផលសិប្បកម្ម, ការជិះស្គីលើទឹកកក
និងការសម្ដែងរបស់ ស៊ីលី សាលី - នៅ JFK Plaza
ម៉ោង 2 រសៀល បញ្ចាំងភាពយន្ត នៅមជ្ឈមណ្ឌល LNHP Visitor Center
ម៉ោង 3:30 រសៀល - 5:30 ល្ងាច កម្មវិធីច្រៀងកំសាន្ត នៅ JFK Plaza
ម៉ោង 4:30 រសៀល - 6:30 ការដើរព្យុហយាត្រា
ដោយចាប់ផ្ដើមពីចំណុចផ្លូវ Jackson Street
បញ្ចប់នៅមុខសាលាក្រុង
ម៉ោង 10 ព្រឹក - 4 រសៀល កម្មវិធីដើរទិញទំនិញរបស់ក្មេងៗ នៅ
ផ្ទះឡាត់ ឈ្នាយប្រារី
សូមចូលទៅកាន់គេហទំព័រសម្រាប់ព័ត៌មានបន្ថែម!
LOWELLCITYOFLIGHTS.ORG
កម្មវិធីទាំងនេះចាប់ផ្ដើមចាប់ពីម៉ោង 12 ថ្ងៃត្រង់
12 - 4pm – Hot Chocolate Competition – Downtown Locations
12 - 5pm – Festival of Wreaths – Masonic Temple
1 - 3pm – Pictures With Santa – City Hall
1 - 5pm – Holiday Craft Market, Ice Skating, and Family Show with Silly Sally – JFK Plaza
2pm – Movie – LNHP Visitor Center
3:30 - 5:30pm – Sing-along – JFK Plaza
4:30 - 6:30pm – Holiday Parade – Starts at Jackson Street Ends in front of City Hall
10am - 4pm – Children's Shopping Day – Pollard Library
See website for more info!
LOWELLCITYOFLIGHTS.ORG
Festivities start at 12pm
#LOWELL
THERE'S A LOT TO like.
Greater Merrimack Valley
Convention & Visitors Bureau
adventuresawait
GREATER LOWELL
CHAMBER OF COMMERCE
SATURDAY, NOVEMBER 24, 2018 • LIKELOWELL.COM